California
Secretary of State

# ការពិតដ៏សង្ខេបសម្រាប់ការបោះឆ្នោតសកលនៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026

**កាលកំណត់សំខាន់ៗ៖**

ថ្ងៃចុងក្រោយសម្រាប់ខោនធីនានាចាប់ផ្តើមការបោះឆ្នោតតាមសំបុត្រ.................................................................................ថ្ងៃទី 5 ខែតុលា
ថ្ងៃចុងក្រោយក្នុងការចុះឈ្មោះបោះឆ្នោត.............................ថ្ងៃទី 19 ខែតុលា
លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត.......ថ្ងៃទី 20 ខែតុលា - ថ្ងៃទី 3 ខែវិច្ឆិកា
សន្លឹកឆ្នោតទាំងអស់ត្រូវតែផ្ញើមកវិញ*..............................ថ្ងៃទី 3 ខែវិច្ឆិកា

*សន្លឹកឆ្នោតទាំងអស់ដែលផ្ញើមកវិញតាមប្រៃសណីយ៍ត្រូវតែបោះត្រាប្រៃសណីយ៍នៅថ្ងៃ ឬមុនថ្ងៃទី 3 ខែវិច្ឆិកា។

## តើខ្ញុំចុះឈ្មោះបោះឆ្នោតដោយរបៀបណា?

ចុះឈ្មោះបោះឆ្នោត ឬធ្វើឲ្យបច្ចុប្បន្នភាពចំពោះការចុះឈ្មោះតាមអនឡាញរបស់អ្នក នៅ registertovote.ca.gov។ ប្រសិនបើអ្នក ចង់បំពេញពាក្យស្នើសុំចុះឈ្មោះបោះឆ្នោតជាក្រដាស នោះពាក្យចុះឈ្មោះអ្នកបោះឆ្នោតអាចរកបាននៅការិយាល័យសំបុត្រ ការិយាល័យបោះឆ្នោតប្រចាំខោនធី និងបណ្ណាល័យនានា។

## ចុះប្រសិនបើខ្ញុំខកកាលបរិច្ឆេទផុតកំណត់ចុះឈ្មោះបោះឆ្នោតវិញនោះ?

ប្រសិនបើអ្នកខកខានកាលបរិច្ឆេទកំណត់ចុះឈ្មោះបោះឆ្នោត អ្នកនៅតែអាចទៅកាន់ការិយាល័យបោះឆ្នោតនៃ ខោនធីរបស់អ្នក មណ្ឌលបោះឆ្នោត ឬទីតាំងបោះឆ្នោត នៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោតដើម្បីបំពេញការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌ (ជារឿយៗហៅថា “ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយ”)។ សូមទាក់ទងការិយាល័យរៀបចំការបោះឆ្នោតនៃខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម ឬចូលទៅកាន់ vote.ca.gov។

## ចុះប្រសិនបើខ្ញុំត្រូវការពិនិត្យស្ថានភាពនៃការចុះឈ្មោះអ្នកបោះឆ្នោតរបស់ខ្ញុំវិញនោះ?

ដើម្បីពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក, អ្នកអាចប្រើឧបករណ៍ “ស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ” នៅ voterstatus.sos.ca.gov។

## តើខ្ញុំនឹងទទួលបានសន្លឹកឆ្នោតរបស់ខ្ញុំនៅពេលណា?

អ្នកបោះឆ្នោតដែលបានចុះឈ្មោះសកម្មទាំងអស់នឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍សម្រាប់ការបោះឆ្នោតសកលថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026។ ថ្ងៃទី 5 ខែតុលា ឆ្នាំ 2026 គឺជាថ្ងៃចុងក្រោយសម្រាប់ខោនធីនានាដើម្បីចាប់ផ្តើមផ្ញើសន្លឹកឆ្នោត។

## តើខ្ញុំនឹងទទួលបានសេចក្តីណែនាំអំពីការបោះឆ្នោតផ្លូវការរបស់រដ្ឋនៅពេលណា?

អ្នកចុះឈ្មោះបោះឆ្នោតហើយនឹងទទួលបានសេចក្តីណែនាំអំពីការបោះឆ្នោតផ្លូវការរបស់រដ្ឋរបស់ពួកគេពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត។ វា ក៏នឹងមានផ្តល់ជូនតាមអនឡាញនៅ voterguide.sos.ca.gov ផងដែរ។

## ចុះប្រសិនបើខ្ញុំត្រូវការសន្លឹកឆ្នោតជំនួស?

ប្រសិនបើអ្នកមិនបានទទួលសន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ ឬសន្លឹកឆ្នោតដើមរបស់អ្នកបានបាត់ ឬខូចខាត អ្នកអាចដាក់ពាក្យសុំសន្លឹកឆ្នោតជំនួស។ ពាក្យសុំសម្រាប់សន្លឹកឆ្នោតជំនួសត្រូវអាចរកឃើញនៅ https://elections.cdn.sos.ca.gov/vote-by-mail/pdf/replacement-application.pdf។

អ្នកក៏អាចស្នើសុំសន្លឹកឆ្នោតប្តូរថ្មីពីការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នកតាមទូរសព្ទ អ៊ីមែល ទូរសារ ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតបានផងដែរ។

## តើខ្ញុំអាចផ្ញើសន្លឹកឆ្នោតរបស់ខ្ញុំទៅវិញដោយរបៀបណា?

អ្នកអាចផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ៖

- **ដោយទម្លាក់ក្នុងប្រអប់**៖ អ្នកអាចយកសន្លឹកឆ្នោតរបស់អ្នកដោយផ្ទាល់ទៅកាន់ការិយាល័យបោះឆ្នោត ឬទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយនៅក្នុងរដ្ឋ California មុនម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត។
- **ដោយផ្ទាល់**៖ ទីតាំងបោះឆ្នោតត្រូវបានបង្កើតឡើងដោយមន្ត្រីរៀបចំការបោះឆ្នោតខេត្ត ហើយបើកចាប់ពី **7:00 ព្រឹករហូតដល់ 8:00 យប់នៅថ្ងៃបោះឆ្នោត ថ្ងៃអង្គារទី 3 ខែវិច្ឆិកា ឆ្នាំ 2026**។ ដើម្បីស្វែងរកទីតាំងដើម្បីបោះឆ្នោតមុនកំណត់ មុនថ្ងៃបោះឆ្នោត សូមចូលទៅកាន់ caearlyvoting.sos.ca.gov។
- **តាមសំបុត្រ**៖ ផ្ញើសន្លឹកឆ្នោតរបស់អ្នកមកវិញតាមប្រៃសណីយ៍ឲ្យបានឆាប់តាមដែលអាចធ្វើបានក្រោយពីអ្នកទទួលបានសន្លឹកឆ្នោតនេះ។ ដើម្បីឲ្យគេរាប់សន្លឹកឆ្នោតនេះ សន្លឹកឆ្នោតរបស់អ្នកត្រូវតែបោះត្រាប្រៃសណីយ៍មុនថ្ងៃបោះឆ្នោត។ យើងសូមណែនាំឲ្យផ្ញើវាមកវិញយ៉ាងហោចណាស់ 7 ថ្ងៃមុនថ្ងៃបោះឆ្នោត។ ប្រសិនបើអ្នកផ្ញើសន្លឹកឆ្នោតមកវិញកៀកនឹងថ្ងៃបោះឆ្នោត សូមយកសន្លឹកឆ្នោតនេះទៅកាន់ការិយាល័យប្រៃសណីយ៍អាមេរិក និងស្នើឲ្យបុគ្គលិកប្រៃសណីយ៍បោះត្រាប្រៃសណីយ៍ដោយដៃ។

## តើខ្ញុំអាចស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត កន្លែងបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតដែលនៅជិតបំផុតរបស់ខ្ញុំដោយរបៀបណា?

- សូមចូលទៅកាន់ caearlyvoting.sos.ca.gov ដើម្បីស្វែងរកប្រអប់សំបុត្រទម្លាក់នៅក្បែរផ្ទះអ្នកបំផុត កន្លែងបោះឆ្នោត ឬទីតាំងមណ្ឌលបោះឆ្នោត។
- សូមទាក់ទង ការិយាល័យបោះឆ្នោតនៃខោនធីរបស់អ្នក។

## តើខ្ញុំអាចតាមដានសន្លឹកឆ្នោតរបស់ខ្ញុំតាមរបៀបណា ដើម្បីដឹងថាសន្លឹកឆ្នោតនេះត្រូវបានទទួល និងរាប់?

អ្នកបោះឆ្នោតអាចទទួលបានការជូនដំណឹងអំពីស្ថានភាពនៃសន្លឹកឆ្នោតដែលបានប្រគល់មកវិញរបស់ពួកគេដោយចុះឈ្មោះសម្រាប់ឧបករណ៍ *“សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?”*។

សូមចុះឈ្មោះនៅ wheresmyballot.sos.ca.gov ដើម្បីទទួលបានព័ត៌មានថ្មីៗដោយស្វ័យប្រវត្តិតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង។

អ្នកក៏អាចចូលទៅកាន់ voterstatus.sos.ca.gov ដើម្បីរកមើលថាតើការបោះឆ្នោតរបស់អ្នកត្រូវបានរាប់ដែរឬទេ។

VOTE CALIFORNIA
SECRETARY OF STATE

**សម្រាប់ព័ត៌មានបន្ថែម និងកាលផុតកំណត់សំខាន់ៗសម្រាប់ការបោះឆ្នោតសកលនៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026 សូមចូលទៅកាន់គេហទំព័រ vote.ca.gov ឬទូរសព្ទទៅលេខទូរសព្ទបន្ទាន់របស់យើងតាមរយៈលេខ (888) 345-4917។**

CALIFORNIA TRUSTED INFO

បានធ្វើឲ្យបច្ចុប្បន្នភាព 07/2026
Khmer